# ព្រះពុទ្ធព្យាករណ៍

អ្នកឧកញ៉ាមហាមន្ត្រី

**ញឹក – នូច**

*រៀបរៀងយ៉ាងសង្ខេប*

*តាមរឿងក្នុងគម្ពីរបាលី*

---

លោកអាចារ្យ

**ប៊ូ – ប៊ូ**

ជួយពិនិត្យមើលខុសត្រូវ

---

ព.ស. ២៥១៣ គ.ស. ១៩៦៩

រំលែកឃើញពីលោក ចៅ ឃុនសំរឹង ផ្តល់ករុណាខ្មែរ ដើម្បីតំកល់ទុក
elibrary of cambodia ប្រចាំខែ កក្កដា 2015

# ព្រះពុទ្ធព្យាករណ៍

អ្នកឧកញ៉ាមហាមន្ត្រី

**ញឹក – នូច**

*រៀបរៀងយ៉ាងសង្ខេប*

*តាមរឿងក្នុងគម្ពីរបាលី*

---

លោកអាចារ្យ

**ម៊ូ – ម៉ូ**

ជួយពិនិត្យមើលខុសត្រូវ

---

ព.ស. ២៥១៣ គ.ស. ១៩៦៩



ព្រះបាទបសេនក្រាបបង្គំគាល់ព្រះសម្ពុទ្ធជាម្ចាស់

នាមអស់លោក អ្នកមានសទ្ធាជ្រះថ្លា

ចូលចាប់មគ្គផលក្នុងធម្មទាននេះផង គឺ :

១- អ្នកឧកញ៉ា ពៅ-ច្រឹប អ្នកស្រី រស់

និងកូនប្រុសស្រី (ជាប្អូនខ្ញុំ) ៤០០ ៛

២- លោក ម៉ែន-លន នាង អរុណា

(ជាក្មួយខ្ញុំ) ១.០០០៛

៣- លោក ម៉ូ-ម៉ុំ អ្នក ហ៊ុន-សិចអ៊ីម ៥០០៛

៤- លោក ផង់ នាង ឡើន (ចៅខ្ញុំ) ៥០០៛

៥- ស្រី លាប់ (ភរិយាខ្ញុំ) ៣០០៛

៦- កុមារានរោ-នួច អាយុ៦ឆ្នាំ(កូនខ្ញុំ) ២០០៛

ខ្ញុំឧកញ៉ាមហាមន្ត្រី ញិក-នួច (រើត្រៃត)

*បានសរសេរបោះពុម្ពរឿងនេះ ក្នុងអាយុគំរប់*

*៧១ឆ្នាំ គឺក្នុងខែ ឧសភា ព.ស. ២៥១៣*

*ត្រូវនឹងខែ មេ៉ត គ.ស. ១៩៦៩ ។*

# បុព្វហេតុ

ព្រះពុទ្ធព្យាករណ៍នេះ

គឺជាមហាសុបិន ១៦ យ៉ាង នៃព្រះបាទ

បសេនទិកោសល

មានក្នុងគម្ពីរមហាសុបិនជាតក

ក្នុងវរវគ្គ ឯកនិបាតវណ្ណនា

ដើមហេតុ : ថ្ងៃមួយ ព្រះធម្មត្រៃលោកាចារ្យ ច័ន្ទ-សាលី គង់វត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ សួរខ្ញុំថា បានជ្រាបរឿង "ព្រះមហាសុបិន ១៦ យ៉ាង ដែរឬទេ ? " ។

ខ្ញុំទូលលោកថា " ពុំដែលបានឮសោះ " ។

ព្រះធម្មត្រៃលោក ក៏ដំណាលប្រាប់ខ្លះៗច្បោលៗ ហើយពន្យល់ថា បើចង់ជ្រាបឱ្យហួរហែច្បាស់លាស់

សូមអញ្ជើញទៅសួរលោកគ្រូ ម៊ូ-ម៉្វ ជាអាចារ្យរបស់អាត្មាភាព ។ ខ្ញុំមានចិត្តសោមនស្សចង់ដឹងឱ្យចប់រឿងនេះ ខ្ញុំពេញចិត្តនឹងសួរលោកអាចារ្យ ម៊ូ-ម៉្វ ទៀត ដែលជាកល្យាណមិត្ររបស់ខ្ញុំ ក្នុងព្រះពុទ្ធ-សាសនា ព្រោះថា កាលបើខ្ញុំទាល់ធមិអាថិណាមួយជាភាសាបាលី ខ្ញុំតែងទៅរកលោក ម៊ូ-ម៉្វ សុំឱ្យលោកមេត្តាពន្យល់ធមិអាថិនោះ ។

លោកអាចារ្យ ម៊ូ-ម៉្វ ទោះបីមានរោគហឺតធ្ងន់ប្រចាំកាយក៏ដោយ ក៏លោកនៅតែព្រមទទួលដោយចិត្តសោមនស្ស ប្រឹងកត់ព្រះសុបិន ១៦យ៉ាង បន្តិចៗក្នុង ១ ខ ឱ្យមកខ្ញុំ ហើយដំណាលរឿងវែងៗឱ្យខ្ញុំស្តាប់ថែមទៀតផង ។ ខ្ញុំក៏ចាំបានយកមករៀបរៀងជាសេចក្តីសង្ខេបដូចមានតទៅនេះ ។

ខ្ញុំមានអំណរគុណចំពោះព្រះធម្មត្រៃលោកាចារ្យ ច័ន្ទ-សាលី និងលោកអាចារ្យ ម៉ូ-ម៉ូ ជាភិយ្យោភាព ។

កាលខ្ញុំសរសេររឿងនេះចប់ហើយ បានយកទៅប្រគេនព្រះធម្មត្រៃលោកាចារ្យ និងលោកអាចារ្យ ម៉ូ-ម៉ូ ពិនិត្យមើលទៀត ហើយសូមឱ្យលោក ម៉ូ-ម៉ូ បញ្ចូលព្រះពុទ្ធភាសិតនៅខាងចុងពុទ្ធព្យាករណ៍មួយៗនោះផង ។ លោកទាំងពីរ ក៏បានពិនិត្យឃើញថាត្រឹមត្រូវហើយ ។

យើងខ្ញុំ សូមឧទ្ទិសផលានិសង្សនៃធម្មទាននេះចំពោះបុព្វការីជនទាំងអស់ មានមាតាបិតា ព្រះឧបជ្ឈាយាចារ្យជាដើម សូមលោកទាំងនោះបានសម្រេចព្រះនិព្វាន ។

# បញ្ជីរឿងក្នុងព្រះពុទ្ធព្យាករណ៍

ទំព័រ


ព្រះពុទ្ធព្យាករណ៍ .................................... ១

១- គោឧសភ ៤ ប្រុងនឹងជល់គ្នា .................................... ៦

២- ដើមឈើតូច ៗ មានផ្កាផ្លែ .................................... ៨

៣- មេគោបៅដោះកូនគោ .................................... ៩

៤- គេទិមកូនគោតូច១ អូសនឹមមិនរួច .................................... ១០

៥- សេះមួយមានក្បាលពីរ មានមាត់ពីរ .................................... ១១

៦- គេយកភាជន៍មាសត្រងទឹកនោមឆ្កែចចក .... ១៣

៧- ឆ្កែចចកញីស៊ីខ្សែដែលបុរសវេញអស់ .................................... ១៤

៨- ក្អមមួយធំមានទឹកពេញពោរ .................................... ១៥

៩- ស្រះបោក្ខរណីមានទឹកស្អាតតែត្រង់កណ្តាល ១៧

១០- បាយ ១ឆ្នាំង ជ្រាយខ្លះ ឆៅខ្លះ ឆ្អិនខ្លះ .......... ១៩

១១- គេយកខ្លឹមចន្ទន៍ទៅដូរយកទឹកដោះស្អុយ....... ២០

ទំព័រ

១២-សម្បកឃ្លោកលិចបាត់ទៅក្នុងទឹក ................ ២២

១៣-ដុំថ្មធំប៉ុនផ្ទះអណ្តែតលើទឹកដូចទូក.................. ២៥

១៤-កូនកង្កែបដេញខាំស៊ីពស់វែកធំ ៗ ................ ២៧

១៥-រាជហង្សមាសចោមរោមក្អែក ........................ ២៨

១៦-ពពែដេញខាំស៊ីខ្លា .......................................... ៣០

# បញ្ជាក់ឈ្មោះគម្ពីរ

## ដែលមានព្រះពុទ្ធភាសិតក្នុងសៀវភៅនេះ

| ឈ្មោះកាត់ | ឈ្មោះពេញ |
| --- | --- |
| ខុ.ធ. .................. | ខុទ្ទកនិកាយ ធម្មបទគាថា |
| ខុ.ឧ. .................. | ខុទ្ទកនិកាយ ឧទាន |
| ជា...................... | ជាតក |
| ម-ម................. | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ |
| វិ-ស................. | វិសុទ្ធិមគ្គ សីលនិទ្ទេស |
| សំ.ស................. | សំយុត្តនិកាយ សគាថាវគ្គ |
| អង្គុ.តិក............ | អង្គុត្តរនិកាយ តិកនិបាត |

# ព្រះពុទ្ធព្យាករណ៍

តាមរឿងគម្ពីរជាតកបាលីថា រាត្រីមួយ ព្រះបាទបសេនទិកោសល ទ្រង់ផ្ទុំស្គល់ បានឃើញព្រះសុបិននិមិត្ត ១៦ យ៉ាង បន្តបន្ទាប់គ្នា តាំងពីវេលារាត្រីរំលងអាធ្រាត្ររហូតដល់អរុណជិតនឹងរះ ទើបព្រះអង្គតើនឡើងតក់ស្លុតព្រះរាជហឫទ័យយ៉ាងខ្លាំង ទាល់តែទ្រង់ផ្ទំទៅវិញលែងលក់ ។ លុះដល់ភ្លឺច្បាស់ឡើង ទ្រង់មានព្រះរាជឱង្ការហៅព្រាហ្មណ៍បុរោហិតឱ្យចូលមកក្រាបបង្គំគាល់ ហើយទ្រង់ត្រាស់ប្រាប់បុរោហិតអំពីព្រះសុបិននិមិត្តទាំង ១៦ យ៉ាងនេះ តាមដែលព្រះអង្គបានចាំច្បាស់លាស់ រួចទ្រង់ត្រាស់សួរបុរោហិតថា " នែបុរោហិត ! សុបិននិមិត្តទាំង ១៦ យ៉ាង ដែលយើងឃើញពីយប់មិញនោះ តើនឹងកើតមានហេតុភេទជាគុណ ឬជាទោសយ៉ាងណា ចូរអ្នក

ទស់ទាយឱ្យយើងស្ដាប់ផង ដ្បិតយើងព្រួយចិត្តគិតបារម្ភណាស់ ។

ព្រាហ្មណ៍បុរោហិតបានស្ដាប់ ព្រះសុបិននិមិត្តទាំង ១៦ យ៉ាងចប់សព្វគ្រប់ហើយ ក៏ឥតយល់ហេតុផលល្អ ឬអាក្រក់អ្វីសោះ ប៉ុន្តែសំដែងអាការថាខ្លួនជាអ្នកប្រាជ្ញ អាចយល់ហេតុផលក្នុងព្រះសុបិននោះច្បាស់លាស់ណាស់ ក៏ទាយថ្វាយថា :

សូមទ្រង់ព្រះមេត្តាប្រោស! ព្រះសុបិននិមិត្តទាំង ១៦យ៉ាងនេះ នឹងកើតមានគ្រោះកាច ៣ ប្រការគឺនឹងអន្តរាយរាជសម្បត្តិ ១, ព្រះអង្គនឹងមានព្រះរោគាពាធជាទម្ងន់ជាប់រហូតទៅ ១ ឬមួយព្រះអង្គនឹងសោយព្រះទីវង្គត១ ទាំង ៣ ប្រការនេះ មុខជាមានប្រការណាមួយដល់ព្រះអង្គពុំខានឡើយ ។ ហេតុ

នេះ ត្រូវតែរៀបចំធ្វើពិធីបូជាយ័ញ្ញឱ្យឆាប់ៗ ទើបអាចនឹងការពារគ្រោះកាចទាំង ៣ ប្រការនេះបាន ។

ព្រះបាទបសេនទិកោសល ទ្រង់ព្រះវិតក្កតក់ស្លុតណាស់ ក៏ត្រាស់បង្គាប់បុរោហិតឱ្យចាត់ការធ្វើពិធីបូជាយ័ញ្ញនោះយ៉ាងប្រញាប់ ។ ព្រាហ្មណ៍បុរោហិត ទទួលព្រះរាជឱង្ការដិកល់លើត្បូង ហើយក៏ក្រាបថ្វាយបង្គំលាចេញទៅចាត់ការនោះ ដោយរួសរាន់ ។

គ្រានោះ ព្រះនាងមល្លិការទេវីជាព្រះអគ្គមហេសីពុំបានជ្រាបហេតុនោះផងសោះ ក៏ចូលទៅក្រាបបង្គំថ្វាយសេចក្ដីទូលសួរថា " បពិត្រព្រះសម្មតិទេព ! ចុះមានបើកើតហេតុភេទអ្វីជាចម្លែក បានជាពួកព្រាហ្មណ៍រត់ប្រសាចចេញព្រះបរមរាជវាំង តើគេប្រុង

ប្រៀបនឹងធ្វើពិធីការអ្វី ? ខ្ញុំម្ចាស់ពុំបានដឹងរឿងរ៉ាវ សោះ សូមព្រះអង្គព្រះរាជទានទោស ប្រោសព្រះ រាជទានព្រះរាជឱង្ការខ្លះផង " ។

ព្រះបាទបសេនទិកោសល ក៏ព្រះរាជទានរឿងព្រះ មហាសុបិនទាំង ១៦ យ៉ាង ដល់ព្រះនាងទេវីមល្លិកា ស្ដាប់ ។ កាលព្រះនាងមល្លិកាទេវីស្ដាប់ចប់ហើយ ក៏ក្រាបទូលស្នើថា " បពិត្រព្រះនរបតីក្សត្រថ្លៃប្រសើរ អើយ ! ព្រាហ្មណ៍ដែលមានឫទ្ធានុភាពខ្លាំងពូកែជាង គេបំផុតក្នុងលោកនេះ និងទេវលោក ម្ដេចក៏ព្រះអង្គ ពុំស្ដេចយាងទៅពិគ្រោះជាមួយផង ?

ព្រះរាជាទ្រង់ត្រាស់ដណ្ដឹងថា " ចុះនរណាដែល មានឫទ្ធានុភាពខ្លាំងពូកែជាងគេបំផុត ម្នាលនាង ?

ព្រះនាងក្រាបបង្គំថ្វាយសេចក្ដីថា " សម្ដេច

ព្រះបរមសម្មាសម្ពុទ្ធជាអម្ចាស់នៃយើង " ។

ព្រះរាជា ក៏ទ្រង់ស្តេចយាងភ្លាមទៅក្រាបថ្វាយបង្គំអង្គសម្តេចព្រះពិជិតមារនាវត្តព្រះជេតពន ។

ព្រះពុទ្ធអង្គទ្រង់មានព្រះតម្រាស់សួរថា "មហារាជ ស្តេចយាងមកទាំងព្រលឹមស្រាងៗ នេះ តើមានបើកើតហេតុភេទអ្វីជាចម្លែកឬ ?

ព្រះរាជាទ្រង់ក្រាបបង្គំទូលថ្វាយសេចក្តីតាមដំណើរថា

" សូមទ្រង់ព្រះមេត្តាប្រោស ! ទូលព្រះបង្គំជាខ្ញុំយប់មិញយល់សប្តិឃើញនិមិត្ត ១៦ យ៉ាងប្លែកពេកណាស់ ។ ខ្ញុំព្រះអង្គភិតភ័យជាពន្លឹក នឹកឃើញព្រមហាករុណាទិគុណ បានជារត់មកក្នុងវេលានេះក្រាបក្រោមព្រះបាទយុគល សូមទ្រង់ព្រះមេត្តាដោះស្រាយសុបិននិមិត្ត ជាប្រស្នាទាំង ១៦ យ៉ាងនេះ

ប្រោសព្រះរាជទាន ។

ព្រះរាជាក៏ទ្រង់ទូលសួរម្តងមួយ ៗគ ៗ គ្នាតាមលំដាប់ព្រះរាជសុបិននិមិត្ត ដូចរៀបរាប់តទៅ :

## ព្រះសុបិនទី ១

ខ្ញុំព្រះអង្គឃើញគោឧសភ ៤ បោលមកពីចម្ងាយសំដែងអាការរៀងខ្លួន ស្រែករោទ៍ហាក់ដូចជានឹងជល់គ្នានៅមុខបណ្តាជនជាច្រើនរយនាក់ ប៉ុន្តែវាបែរជាពុំជល់គ្នាទេវិញ ។

តើសុបិនទី ១ នេះ បានសេចក្តីដូចម្តេច សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ?

សម្តេចព្រះភគវា ទ្រង់ព្រះរាជទានន័យព្យាករថា "មហារាជ កុំព្រួញព្រះរាជហឫទ័យឡើយ គ្មានហេតុផលអ្វីកើតដល់ព្រះអង្គទេ ។ ប៉ុន្តែដល់ទៅអនាគតកាល មនុស្សលោកមិនតម្រង់ចិត្តឱ្យស្ថិត

នៅក្នុងសុចរិតយុត្តិធម៌ ចេះតែបបួលគ្នាប្រព្រឹត្ត ទុច្ចរិតអយុត្តិធម៌ទៅវិញ ជាហេតុបណ្ដាលឱ្យទឹកភ្លៀងធ្លាក់មិនត្រឹមត្រូវតាមរដូវកាល ។ ស្រូវក្នុងស្រែស្វិតក្រៀម សន្ទូងងាប់អស់ កើតអត់បាយក្រហាយទឹក ។ បើទុកជាមេឃងងឹតផ្គរលាន់គគ្រឹមផ្លេកបន្ទោរច្រវាត់ហាក់ដូចជានឹងស្រក់ភ្លៀងឥឡូវ ក៏បែរជារាំងគ្មានភ្លៀងសោះទៅវិញ បីដូចជាគោឧសភចង់ជល់គ្នាហើយត្រឡប់ជាមិនជល់គ្នា ដូចក្នុងព្រះសុបិននោះឯង ។

**ព្រះពុទ្ធភាសិត**

យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។អតិយសច្ច។

ចង់បានអ្វី ៗ ហើយ ពុំបានតាមបំណង តែងតែកើតទុក្ខទោមនស្ស ។

## ព្រះសុបិនទី ២

ព្រះរាជា- ខ្ញុំព្រះអង្គឃើញដើមឈើតូច កំពស់មួយហត្ថខ្លះ មួយតក់ខ្លះ មានផ្កាផ្លែ ។

ព្រះពុទ្ធ- ទ្រង់ព្យាករថា មហារាជអើយ អំណើះទៅខាងមុខ មនុស្សសត្វ នឹងមានអាយុខ្លី ប្រកបដោយរាគៈតម្រេកខ្លាំងក្លាណាស់ ។ កុមារី មិនទាន់គ្រប់ការសុខចិត្តសេពមេថុននឹងបុរស ទាល់តែមានរដូវមានគភ៌ហើយមានកូនប្រុសស្រី បីដូចរុក្ខជាតតូច ៗ មានផ្កាផ្លែ ដូចដែលព្រះអង្គឃើញនោះ ។

### ព្រះពុទ្ធភាសិត

នត្ថិ រាគសមោ អគ្គិ ។ ខុ.ធ. ។

គ្មានភ្លើងអ្វីក្តៅខ្លាំងស្មើនឹងរាគៈ គឺ ចិត្តត្រេកត្រអាលក្នុងអំពើពាលផ្សេង ៗ មានមេថុនជាដើមនោះទេ ។

## ព្រះសុបិនទី ៣

ព្រះរាជា- ខ្ញុំព្រះអង្គឃើញមេគោបៅដោះកូនគោ ។

ព្រះពុទ្ធ- មហារាជដ៏ចំរើនអើយ ! អំណើះទៅខាងមុខ ពួកក្មេង ៗ ពុំគោរពកោតខ្លាចចាស់ព្រឹទ្ធាចារ្យទេ ។ សូម្បីតែកូនចៅ ក៏ពុំគោរពប្រតិបត្តិមាតាបិតាជីដូនជីតាឡើយ ។ ចេះតែគិតតែលៃលកប្រមូលយកទ្រព្យសម្បត្តិអំពីមាតាបិតាជាដើម ទុកជារបស់ខ្លួន តាំងពីសម្លៀកបំពាក់រហូតដល់គ្រឿងបរិភោគ ។ គេដាច់ចិត្តលែងនឹកនាដល់មនុស្សចាស់ជរា លែងចិញ្ចឹមថែរក្សា ។ លុះត្រាតែពួកចាស់ ៗ ទាំងនោះនៅបំរើមើលកូនចៅឱ្យគេ ទើបគេទទួលចិញ្ចឹម ដូចមេគោបៅដោះកូនគោនោះឯង ។

## ព្រះពុទ្ធភាសិត

ជិឃច្ឆា បរមា រោគា ។ខុ.ធ.។

សេចក្តីស្រេចឃ្លាន ជាជម្ងឺរោគាយ៉ាងធ្ងន់
បំផុតក្រៃលែង ជាងរោគាព្យាធិនានា ។

## ព្រះសុបិនទី ៨

ព្រះរាជា- ខ្ញុំព្រះអង្គឃើញគេទឹមកូនគោតូច ៗ ដែលវាអូសនឹមមិនរួច ។

ព្រះពុទ្ធ- ថ្វាយព្រះពរ ! អំណើះទៅខាងមុខ ពួកព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតកវី ដែលជាអ្នកឈ្លាសវៃ ចេះចាំលទ្ធិប្រពៃណី ពុំបានធ្វើជាមន្ត្រីស្ដីការក្នុងសាលាកាត់ក្តីទេ ។ បែរជាពួកក្មេង ៗ ដែលល្ងង់ខ្លៅបានយសសក្តិ ធ្វើជាចៅក្រមជំនុំជម្រះកាត់ក្តីទៅវិញ តែពុំអាចសម្រេចសេចក្តីឱ្យបណ្តារាស្ត្រសុខ

ចិត្តសោះឡើយ ម្ល៉ោះហើយក៏ទម្លាក់ភារៈនោះចោល ដូចកូនគោទម្លាក់ចោលនឹម ដែលវាអូសទាញទៅមិនរួចនោះឯង ។

ព្រះពុទ្ធភាសិត

នត្ថិ ឈានំ អប្បញ្ញស្ស ។ខុ.ធ. ។

មនុស្សឥតបញ្ញា មិនចេះពិនិត្យពិចារណាទេ។

នត្ថិ បញ្ញា អឈាយិនោ ។ខុ.ធ. ។

មនុស្សមិនចេះពិនិត្យ ពិចារណា បញ្ញាមិនដុះដាល់ឡើង ។

## ព្រះសុបិនទី ៥

ព្រះរាជា- ខ្ញុំព្រះអង្គឃើញសេះមួយមានក្បាលពីរ មានមាត់ពីរ ស៊ីស្មៅនឹងមាត់ទាំងពីរនោះ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ អ្នកជម្រះក្តីមិន

តាំងចិត្តឱ្យស្ថិតនៅក្នុងសុចរិតយុត្តិធម៌ទេ ជាមនុស្សពាលល្មោភលោភលន់ពន់ពេក មិនសមាទានសីល មិនឱ្យទាន មិនដឹងបាបបុណ្យគុណទោសសោះ ចេះតែទទួលសំណូកពីកូនក្តី ទាំងខាងឈ្នះ ទាំងខាងចាញ់ ដូចជាសេះស៊ីស្រូវនឹងមាត់ទាំងពីរនោះឯង ។

**ព្រះពុទ្ធភាសិត**

ហនន្តិ ភោគា ទុម្មេធំ ។ ខុ.ធ. ។

ភោគសម្បត្តិតែងសម្លាប់អ្នកឥតបញ្ញា គឺអ្នកធ្វើតែអំពើទុច្ចរិតអយុត្តិធម៌ ។

ម្យ៉ាងទៀតថា សក្ការោ កាបុរិសំ ហន្តិ

សក្ការៈតែងសម្លាប់បុរសស្រ្តីអាក្រក់ ។ ខុ.ធ. ។

## ព្រះសុបិនទី ៦

ព្រះរាជា- ខ្ញុំព្រះអង្គឃើញគេយកភាជន៍មាស ទៅត្រង់ទឹកនោមឆ្កែចចក ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ អ្នកមានត្រកូល ខ្ពង់ខ្ពស់ធ្លាក់ខ្លួនទៅជាទាល់ក្រលំបាក ទាបថោកឥត យសសក្តិ ។ ចំណែកអ្នកមានត្រកូលទាបថោក ទៅជាបានធ្វើមន្ត្រីធំ មានយសសក្តិខ្ពស់ត្រដែត ។ ម៉្លោះហើយ ពួកអ្នកមានត្រកូលខ្ពង់ខ្ពស់ទាំងនោះ ក៏ ដាច់ចិត្តលើកកូនស្រីនៃខ្លួនឱ្យទៅជាភរិយា នៃកូន អ្នកមានត្រកូលថោកថយជាងខ្លួន ដើម្បីនឹងឱ្យបាន ងាយស្រួលក្នុងការរស់នៅ ដូចជាឆ្កែចចកជាតិ តិរច្ឆាននោមដាក់ភាជន៍មាសនោះឯង ។

ព្រះពុទ្ធភាសិត

នត្ថិ ភាមា បរំ ទុក្ខំ ។ជា.។

ពុំមានទុក្ខណា ធ្ងន់ក្រៃលែងជាងកាមគុណទេ

## ព្រះសុបិនទី ៧

ព្រះរាជា- ខ្ញុំព្រះអង្គឃើញឆ្កែចចកញីស៊ីខ្សែ ដែលបុរសវេញរួចហើយទាល់តែអស់ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ ពួកស្ត្រីមានរាគៈ គឺតម្រេកខ្លាំងក្លា ចូលចិត្តតែក្រេបផឹកសុរា ស្រឡាញ់ តែគ្រឿងអលង្ការតាក់តែងរាងកាយ សប្បាយតែ ខាងការត្រាចចរតាមច្រកល្ហករកប្រុសសហាយ ឥត រក្សាសីលធ្វើទានសោះ សូម្បីតែការងារក្នុងផ្ទះ សម្បែងក៏លែងធ្វើដែរ ។ ឯប្តីលំបាកចិត្តណាស់ ឥតបានសុខសាន្តទេ ព្រោះទុកប្រាក់កាសមិនចេះ

គង់ ដោយហេតុប្រពន្ធក្បត់ចិត្តគិតតែពីចាយវាយខ្ជះខ្ជាយ ដូចជាឆ្កែចចកញីស៊ីខ្សែដែលបុរសវេញទុកស្រេចហើយ ទាល់តែអស់ដូច្នោះឯង ។

### ព្រះពុទ្ធភាសិត

**ភាមេហិ លោកម្ហិ ន ហត្ថិ តិត្តិ** ។ម.ម.។

មនុស្សបុថុជ្ជនក្នុងលោកិយនេះមិនចេះឆ្អែតឆ្អន់នឹងកាមគុណទេ ។

### ព្រះសុបិនទី ៨

ព្រះរាជា- ខ្ញុំព្រះអង្គឃើញក្អមមួយធំមានទឹកពេញប្រៀប មានក្អមទទេជាច្រើនព័ទ្ធជុំវិញ ។ មានពួកមនុស្សមកពីទិសទាំង ៨ នាំគ្នាប្រឹងដងទឹកចាក់តែក្នុងក្អមធំ ១ នៅត្រង់កណ្តាល ដែលមានទឹកពេញ

ស្រាប់ទៅហើយនោះ ឥតមាននរណាម្នាក់ចាប់ភ្លឹកចាក់ទឹកទៅក្នុងក្អមទទេទាំងនោះសោះឡើយ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ មនុស្សលោកនឹងប្រែប្រួល គឺថាបណ្ដាអ្នកកំសត់ទុគតិ នាំគ្នាជញ្ជូនប្រាក់កាសរាបរយពាន់ ទៅបំពេញតែទូហិបអ្នកមានធនធានស្រាប់ ថែមទាំងត្រូវកំណែនទៅធ្វើស្រែចំការច្បារដំណាំឱ្យអ្នកធំ អ្នកស្ដុកស្ដម្ភទៀតចោលរបររបស់ខ្លួនអស់ ខំបេះយកផលជញ្ជូនទៅដាក់ឃ្លាំងអ្នកមានសម្បត្តិ ឥតឱកាសនឹងធ្វើការងាររបស់ខ្លួនឯងឡើយ ដូចជាក្អមទទេ ឥតមាននរណាចាប់ភ្លឹកនឹកនាសោះ ទៅជាគិតតែចាក់ទឹកបំពេញក្អមធំដែលមានទឹកពេញពោរស្រាប់ហើយនោះឯង ។

## ព្រះពុទ្ធភាសិត

ឥស្សរិយំ លោកេ ។សំ.ស.។

អំណាច ជាធំក្នុងលោក ។

## ព្រះសុបិនទី ៩

ព្រះរាជា- ខ្ញុំព្រះអង្គឃើញស្រះបោក្ខរណីមួយ មានទឹកល្អក់តែត្រង់កណ្តាល ។ ឯទឹកតាមឆ្នេរច្រាំងជុំវិញ ដែលមានមនុស្សសត្វចុះអាស្រ័យទឹកនោះ បែរទៅជានៅថ្លាស្អាតល្អឥតកករល្អក់សោះ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ មន្ត្រីមានចិត្តមិនបរិសុទ្ធ រមែងប្រកបដោយអគតិធមិទាំង ៤ កាត់ក្តីមិនត្រឹមត្រូវតាមផ្លូវច្បាប់ សំឡឹងចង់បានតែទ្រព្យគេ គ្មានព្រហ្មវិហារចំពោះបណ្តារាស្ត្រសោះ ចិត្តកាចឃោរឃៅ ធ្វើបាបខ្លាំងពេកទាល់តែពួកបណ្តារាស្ត្រ

នាំគ្នារត់ចោលស្រុកកំណើត ទៅនៅចុងកាត់មាត់ញក នៅនាព្រៃភ្នំក្រំថ្មឯណោះវិញ ទើបបានសុខស្រួល ដូចជាស្រះបោក្ខរណីដែលមានទឹកល្អក់ត្រង់កណ្ដាល មានទឹកថ្លាតាមឆ្នេរខាងនោះឯង ។

**ព្រះពុទ្ធភាសិត**

ន សន្ថវស្មា បរមត្ថិ បាបិយោ
យោ សន្ថវោ កាបុរិសេន ហោតិ ។ជា. ។

ការសេពគប់ស្និទ្ធស្នាលនឹងមនុស្សពាលអប្បុរសជាការអាក្រក់(នាំឱ្យកើតទុក្ខទោស)យ៉ាងក្រៃលែង ។ សូវរត់ចោលស្រុកប្រសើរជាងសេពគប់នឹងពាល ។

# ព្រះសុបិនទី ១០

ព្រះរាជា- ខ្ញុំព្រះអង្គឃើញអ្នកគ្រួដាំបាយមួយឆ្នាំង មានឆ្អិនខ្លះ ឆៅខ្លះ ជ្រាយខ្លះ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ ស្រុកទេសនឹងកើតហេតុភេទ ៣ យ៉ាង ហើយនឹងឱ្យផលដូចតទៅនេះ :

១- ពួកមនុស្សទាំងអស់ តាំងពីមន្ត្រី, គហបតី និងសមណព្រាហ្មណ៍ គ្រប់ស្រុកភូមិ វត្តអារាម មិនប្រកបដោយសីលធម៌ទេ ។

២- ពួកអារក្ខទេវតា , រុក្ខទេវតា, អាកាសដ្ឋកទេវតា ទាំងអម្បាលមាណ មិនកាន់សីលធម៌ឡើយ ម្ល៉ោះហើយ អាកាសក៏ប្រែប្រួល រមែងមានខ្យល់បោកបក់មិនស្មើភូមិភាគ ភ្លៀងក៏បង្អុរចុះមិនសព្វគ្រប់ទិសទី មិនសព្វគ្រប់ស្រែចំការ ។ ដំណាំ

ទាំងអស់ពុំបានផលល្អបរិបូណ៌ ។

៣- នៅភូមិភាគខ្លះមានភ្លៀងធ្លាក់ច្រើនពេក ទាល់តែរលួយសំណាបសន្ទូងអស់ មិនបានផល គ្រាន់នឹងបរិភោគឡើយ ដូចជាបាយមួយឆ្នាំង មានឆ្អិន មានឆៅ មានជ្រាយ យ៉ាងនោះឯង ។

**ព្រះពុទ្ធភាសិត**

**នត្ថិ ភិក្ខវេ បណ្ឌិតតោ ភយំ** ។ អង្គុ.តិក. ។

ម្នាលភិក្ខុទាំងឡាយ! ភ័យមិនដែលកើតអំពីបណ្ឌិតទេ (តែងកើតអំពីពាល) ។

## ព្រះសុបិនទី ១១

ព្រះរាជា- ខ្ញុំព្រះអង្គឃើញគេយកខ្លឹមចន្ទន៍ តម្លៃ ១ សែន ទៅប្តូរយកទឹកដោះគោជូរផ្អមស្អុយ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ ពួកភិក្ខុសង្ឃ

ក្នុងសាសនាតថាគត គិតតែខាងលោភលន់ចង់បាន បច្ច័យ ៤ ព្រមទាំងឋានៈខ្ពង់ខ្ពស់ ឥតអៀនខ្មាស់សោះ ។ ធម៌វិន័យដែលតថាគតបានទេសនាទូន្មានមិនឱ្យត្រេកអរនឹងបច្ច័យ ៤ ទេ មិនឱ្យចង់បានឋានៈអ្វីទេ ឱ្យខំតែកំចាត់បង់លោភៈ ទោសៈ មោហៈចេញឱ្យផុតពីសន្តានចិត្ត ហើយឱ្យខំប្រឹងប្រព្រឹត្តត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា ឱ្យមុតមាំមែនទែន ដើម្បីជាផ្លូវទៅកាន់ព្រះនិព្វាន ។ ប៉ុន្តែ លុះដល់តថាគតចូលនិព្វានកន្លងទៅជាយូរអង្វែងឆ្នាំ ពួកភិក្ខុទាំងឡាយ ប្រែក្លាយទៅជាយកធម៌វិន័យដែលតថាគតសំដែងទូន្មាននោះ ទេសនាបញ្ចេញបញ្ចូលប្រមូលបែបបទឱ្យតែខាងពីរោះ ឱ្យតែបានល្បីល្បាញកេរ្តិ៍ឈ្មោះឈ្នះគេ ដើម្បីនឹងឱ្យ បានលាភសក្ការៈជា

ច្រើន ឱ្យបានឋានៈខ្ពង់ខ្ពស់ ឥតខ្លាចបាប ហ៊ាន យកធមិសម្រាប់ព្រះនិព្វានទៅប្តូរនឹងបច្ច័យ ៤ ព្រមទាំងកិត្តិយស ដូចជាគេយកខ្លឹមចន្ទន៍តម្លៃ ១ សែន ទៅប្តូរយកទឹកដោះគោស្អុយនោះឯង ។

> **ព្រះពុទ្ធភាសិត**
>
> លោភោ ធម្មានំ បរិបន្ថោ ។សំ.ស.។
>
> សេចក្តីលោភលន់ហួសប្រមាណ តែង អន្តរាយធមិសម្រាប់ទៅព្រះនិព្វាន ។

## ព្រះសុបិនទី ១២

ព្រះរាជា- ខ្ញុំព្រះអង្គឃើញសម្បកឃ្លោកលិច បាត់ទៅក្នុងទឹក ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ ដល់កាលណា មនុស្សលោក លែងគោរពប្រតិបត្តិធមិអាថិសិក្ខាវិន័យ

ហើយ កាលនោះស្រុកទេសក៏នឹងប្រែប្រួលពុំបានសុខសាន្តឡើយ ព្រោះអ្នកមានជាតិត្រកូលថោកទាបបានយសសក្តិថ្កើងរុងរឿង ធ្វើជាមន្ត្រីធំជាងអ្នកមានជាតិត្រកូលថ្លៃថ្នូរ ។ ឯអ្នកមានពូជពង្សវង្សត្រកូលថ្លៃថ្នូរ បែរទៅជាទាបថោក ដូចជាសម្បកឃ្លោកដែលជាធម្មជាតិធ្លាប់តែអណ្តែតលើទឹក ក៏ប្រែក្លាយជាធ្ងន់លិចបាត់ទៅក្នុងទឹកវិញ គឺថា បានស្ថិតនៅចំពោះព្រះភក្ត្រព្រះមហាក្សត្រផង បានធ្វើក្នុងរាជការផង ។

ម្យ៉ាងទៀត ភិក្ខុដែលមានសីលមិនបរិសុទ្ធ ជាអ្នកទ្រុស្តសីល នឹងបានឋានៈជាធំក្នុងទីប្រជុំសង្ឃ ។ ឯភិក្ខុដែលមានសីលស្អាតបរិសុទ្ធ ត្រឡប់ជាជនានុជនលែងគោរពរាប់អាន លែងស្តាប់បង្គាប់ ។

គេនាំគ្នាគោរព រាប់អានជឿស្ដាប់តែពាក្យសំដីនៃភិក្ខុ អលជ្ជីទ្រុស្ដសីលទៅវិញ ដូចសម្បកឃ្លោក(១) ត្រឡប់ជាធ្ងន់លិចបាត់ទៅក្នុងទឹកនោះឯង ។

ព្រះពុទ្ធភាសិត

មនុស្សផេគ្គុំ នាសិទេ
យស្មឹ នត្ថិ ភតញ្ញុតា ។ ជា. ។

យើងមិនគួរចូលទៅជិតសេពគប់ស្និទ្ធ ស្នាលនឹងមនុស្សអកតញ្ញូទេ ព្រោះគេ ទុកអ្នកនោះថាដូចជាសម្បកឈើ ឬ សម្បកឃ្លោក ,

(១) ក្រហស្ថ ឬបព្វជិតដែលល្ងង់ខ្លៅ ទ្រុស្ដសីល លោកឱ្យឈ្មោះថា ជាមនុស្សដូចសម្បកឃ្លោក ។ ព្រះពុទ្ធតែងត្រាស់ហៅថា មោឃបុរស ។

## ព្រះសុបិនទី ១៣

ព្រះរាជា- ខ្ញុំព្រះអង្គឃើញថ្មមួយដុំធំប៉ុនផ្ទះអណ្តែតលើទឹកដូចជាទូក ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ សក្តិយសខ្ពង់ខ្ពស់នឹងបានទៅតែខាងពួកអ្នកឥតត្រកូល ។ បានធ្វើជានាហ្មឺនធំ ។ ចំណែកពួកអ្នកមានត្រកូលវិញត្រឡប់ធ្លាក់ខ្លួនទៅជាក្រខ្សត់ អ្នកផងលែងគោរពកោតក្រែង ។ គេនាំគ្នាគោរពកោតខ្លាចតែពួកអ្នកឥតត្រកូលទៅវិញ នោះយ៉ាងណាមិញ ។ ធម្មតាដុំថ្ម ទោះបីតូចក្តី ធំក្តី ជាវត្ថុធាតុមានទម្ងន់ធ្ងន់ណាស់តែងតែលិចចុះទៅក្នុងទឹក ប៉ុន្តែ ដុំថ្មនោះបែរទៅជាស្រាលអណ្តែតលើទឹក រសាត់បាត់ទៅតាមខ្យល់វិញ មិនអាចលិចចុះទៅក្នុងទឹកបាន គឺថា អ្នកមានត្រកូល

មានចំណេះវិជ្ជា មិនបានស្ថិតនៅចំពោះព្រះនេត្រា ព្រះមហាក្សត្រផង ចំពោះមុខសេវកាមាត្យផង ។

ម្យ៉ាងទៀត គេមិនធ្វើគារវកិច្ចចំពោះព្រះសង្ឃ ដែលមានសីលល្អបរិសុទ្ធទេ គេស្រឡាញ់រាប់អាន តែពួកភិក្ខុអលជ្ជីទ្រូស្តសីលវិញ ។ ពួកព្រះសង្ឃ ដែលប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យ ត្រឡប់ជាខ្មាត់ ភ្លាត់ចេញពីទីប្រជុំសង្ឃទៅនៅក្រៅវិញ ឈមមុខ នឹងគេក្នុងទីប្រជុំសង្ឃពុំបានឡើយ ដូចជាដុំថ្មធំដែល អណ្តែតត្រសែតតាមខ្សែទឹកបាត់ទៅនោះឯង ។

**ព្រះពុទ្ធភាសិត**

បតិដ្ឋា កុសលធម្មានំ នត្ថិ សីលំ

ទិសា ៩៨ ។ វិ.សី. ។

កុលបុត្រក្នុងព្រះពុទ្ធសាសនានេះ គ្មានទី ពឹងអ្វីប្រសើរក្រៃលែងជាទីពឹងសីលទេ ។

## ព្រះសុបិនទី ១៤

ព្រះរាជា- ខ្ញុំព្រះអង្គឃើញកូនកង្កែបតូចៗ លោតដេញខាំពស់វែកធំ ៗ ហើយទំពារស៊ីលេបបាត់ទៅ ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ លោកនឹងអាប់ឱន ក្នុងគ្រាដែលមានមនុស្សទាំងឡាយ ប្រកបដោយកំឡាំងកាមរាគដ៏ខ្លាំងខ្លា មានកិលេសតណ្ហាគ្របសង្កត់ជាប់ បណ្ដាលឱ្យប្ដីសុខចិត្តនៅក្រោមអំណាចប្រពន្ធក្មេង ៗ ។ សម្បត្តិទ្រព្យទាំងអស់មានទាសីទាសា គោ ក្របី ដំរី សេះ ជាដើម នៅក្នុងកណ្ដាប់ដៃនៃប្រពន្ធពេញទី ។ បើប្ដីសួរនាំរកសម្បត្តិទ្រព្យផ្សេង ៗ ប្រពន្ធស្ដីបន្ទោសជេរប្រទេចប្រមាថតបតវិញ កំហែងប្ដីឱ្យលុះក្នុងអំណាចខ្លួនស្មើខ្ញុំកំដរ ដូច

ជាកូនកង្កែបតូចៗ ហ៊ានលេបពស់វែកធំៗ នោះឯង ។

**ព្រះពុទ្ធភាសិត**

អប្បមាទោ អមតំ បទំ ។ខុ.ធ. ។

សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់ ។

បមាទោ មច្ចុនោ បទំ ។ខុ.ធ. ។

សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ។

## ព្រះសុបិនទី ១៥

ព្រះរាជា- ខ្ញុំព្រះអង្គឃើញរាជហង្សមាស ចោមរោមក្អែក ។

ព្រះពុទ្ធ- អំណើះទៅខាងមុខ ពួកមហាក្សត្រកូល មិនឈ្លាសវៃក្នុងចំណេះវិជ្ជាផ្សេងៗ ទាំងមិនក្លាហាន ក្នុងចម្បាំងផង ។ ម្ល៉ោះហើយ ព្រះមហាក្សត្រ មិនទ្រង់ប្រោសព្រះរាជទាន យសសក្តិដល់អ្នកមាន

ជាតិស្មើគ្នា បែរទៅជារើសរកយកតែពួកអ្នកគាល់បំរើផ្ទាល់ព្រះអង្គទៅវិញ ។ ពួកកុលបុត្រដែលមានត្រកូលបរិបូណ៌ មិនអាចនឹងចូលមកទីពឹងរាជត្រកូលបានឡើយ មិនអាចនឹងចិញ្ចឹមជីវិតឱ្យបានសុខស្រួលសោះ ។ ម្លោះហើយ លុះដល់លំបាកវេទនាពន់ពេក ក៏ដាច់ចិត្តចូលទៅនៅបំរើពួកអ្នកមានត្រកូលទាបថោក ដែលមានបុណ្យសក្ដិលក្ខិណាជាធំវិញ ដូចជារាជហង្សមាសទៅចោមរោមធ្វើជាបរិវារក្អែកនោះឯង ។

**ព្រះពុទ្ធភាសិត**

នាញ្ញំ និស្សាយ ជីវេយ្យ ។ ខុ.ជា. ។

យើងមិនត្រូវរស់នៅ ដោយសារផ្ញើពោះលើគេទេ ។

## ព្រះសុបិនទី ១៦

ព្រះរាជា- ខ្ញុំព្រះអង្គឃើញពពែដេញខាំស៊ីខ្លា ។ តើសុបិននេះ នឹងមានការប្រែប្រួលទៅជាយ៉ាងណា ? ឱព្រះជាអម្ចាស់ខ្ញុំអើយ ! កាលពីដើម ខ្ញុំព្រះអង្គធ្លាប់តែបានដឹងឮថា "ខ្លាខាំស៊ីពពែ" ។ ឥឡូវ ខ្ញុំព្រះអង្គយល់សប្តិឃើញពពែខាំស៊ីខ្លាវិញ ។ មិនតែប៉ុណ្ណោះ ហ្វូងខ្លាគ្រាន់តែឃើញពពែពីចម្ងាយលឹម ៗ ក៏នាំគ្នាបោលយ៉ាងលឿនចូលទៅនៅក្នុងព្រៃធំខំពួនលាក់ខ្លួនព្រោះខ្លាចពពែខាំស៊ី ។

អង្គសម្តេចព្រះសក្យមុនីសម្មាសម្ពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ព្យាករថា : ថ្វាយព្រះពរមហារាជ ! ចំណោរចេរកាលទៅឯភ្នែក ពួកបណ្ឌជនអ្នកឥតពូជត្រកូល ត្រូវបានសេចក្តីប្រោសប្រាណឡើងធ្វើជា

នាហ្មឺនធំ ។ ឯជនដែលមានពូជត្រកូលខ្ពង់ខ្ពស់ បែរទៅជាអាប់យសសក្តិធ្លាក់ខ្លួនជាក្រខ្សត់វិញ ។ អ្នកធំជឿស្តាប់តែសេចក្តីវិនិច្ឆ័យរបស់មន្ត្រីថ្មី ដែលប្រវ័ញ្ចយកស្រែចំការបណ្តាភាស្រ្តថាជារបស់ខ្លួន ។ ថែមទាំងឱ្យចាប់យកភាស្រ្តខ្លះ មកធ្វើទារុណកម្ម ហើយកំហែងថា ម៉េចក៏ឯងហ៊ានមកតវ៉ានឹងនាហ្មឺន ។ ជួនកាលមានដល់ទៅឱ្យធ្វើទោស កាត់ដៃជើង និងវាយខ្នងផង ។ ម្ល៉ោះហើយ ពួកអ្នកមានពូជត្រកូលគេមករកឃើញចាប់ចងនាំខ្លួនយកទៅធ្វើទោសពៃ ។

ម្យ៉ាងទៀត ក្នុងសាសនាតថាគតនេះ ពួកភិក្ខុទ្រុស្តសីលរករឿងហេតុចាប់ទោស ពួកភិក្ខុជាអ្នកមានសីលបរិសុទ្ធវិញ ដូច្នេះ ពួកភិក្ខុមានសីលស្អាតល្អ

ទាំងនោះ ក៏នាំគ្នារត់ទៅពឹងព្រៃភ្នំក្រំថ្ម ពួនលាក់ខ្លួនដូចជាខ្លាខ្លាចពពែ ហើយខំបោលចូលព្រៃជ្រៅនោះឯង ។

ថ្វាយព្រះពរមហារាជ ! ព្រះសុបិននិមិត្តទាំង ១៦ យ៉ាងនេះ ឥតកើតមានទោសទុក្ខអន្តរាយអ្វី ៗ ដល់ព្រះអង្គសោះឡើយ សូមកុំទ្រង់ព្រួយព្រះរាជហឫទ័យ ។

**ព្រះពុទ្ធភាសិត**

អត្តា ហវេ ជិតំ សេយ្យោ ។ ខុ.ធ. ។

ការឈ្នះខ្លួនឯង ជាជ័យជំនះប្រសើរវិសេសក្រៃលែង ជាងឈ្នះសត្រូវខាងក្រៅរាប់រយពាន់ដង ។

ព្រះពុទ្ធព្យាករណ៍ ១៦ យ៉ាង ចប់ប៉ុណ្ណោះ

## សុភាសិតថ្មី

១- កុំយកខូចជាល្អ កុំយកក្រជាមាន
កុំយកឃ្លានពានជាសុភាព ។

ញ.ន.

---

២- កុំយកល្អជាអាក្រក់ កុំយកផ្កាជាលាមក
កុំលុបគុណធ្វើជាទោស ។

ញ.ន.

---

៣- កុំជឿហោរឱ្យហួស កុំជឿអ្នកបួសឥតវិន័យ
កុំជឿសិរីថាមិនស្លាប់ ។

ញ.ន.

---

៤- អ្នកប្រាជ្ញត្រូវស្គាល់ខុស អ្នកបួសត្រូវស្គាល់វិន័យ
អ្នកកាន់ក្តីត្រូវស្គាល់ច្បាប់ ។

ញ.ន.

---

យើងខ្ញុំជាកូន ខ្ញៅ យុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ រ៉ាមុន
ខ្ញៅ ភារាដា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសល់ដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ យី គិមយ៉ាត

សីហា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា